**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**សាលាខេត្តកោះកុង**

លេខ:១៩៣៧.....ខកក

កោះកុង,ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៤

**<u>ជំរាបជូន</u>**

- **លោក អភិបាលក្រុង ខេមរភូមិន្ទ**
- **លោក អភិបាលស្រុក គ្រប់ស្រុក**

**កម្មវត្ថុ:** ការបើកសិក្ខាសាលាសមាហរណកម្មផែនការឃុំ-សង្កាត់ នៅថ្នាក់ក្រុង/ស្រុក

**យោង:** -ប្រកាសអន្តរក្រសួងលេខ ២៤២៣ ប្រ.ក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៧ របស់ក្រសួងមហាផ្ទៃ និង ក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ឃុំ-សង្កាត់ និង កម្មវិធីវិនិយោគឃុំ-សង្កាត់។

-លិខិតលេខ ៧០៥ ផក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៩ របស់ក្រសួងផែនការ ស្តីពីការរៀបចំដំណើរការសិក្ខាសាលា សមាហរណកម្មផែនការ ឃុំ-សង្កាត់ នៅថ្នាក់ក្រុង/ស្រុក ។

ន័យដូចបានជំរាបជូនក្នុងកម្មវត្ថុ និង យោងខាងលើ អភិបាលខេត្តសូមជំរាបជូន លោក-លោកស្រី ជ្រាបថា: ក្រុមប្រឹក្សាឃុំ-សង្កាត់ ទាំង ២៩ឃុំ-សង្កាត់ បានរៀបចំ កម្មវិធីវិនិយោគឃុំ-សង្កាត់ឆ្នាំ ២០១៥ ពី ជំហាន ទី១ ដល់ជំហានទី២ ត្រូវបានបញ្ចប់(រៀបចំគំរោងអភិវឌ្ឍន៍) ដោយត្រូវបន្តដល់ជំហាន ទី៣ (សមាហរណកម្មផែនការឃុំ-សង្កាត់ នៅថ្នាក់ ក្រុង/ស្រុក ) តាមកាលបរិច្ឆេទដូចមានក្នុងតារាងខាងក្រោម:

| ល.រ | កាលបរិច្ឆេទ | ឈ្មោះក្រុង/ស្រុក | ចំនួន ឃុំ-សង្កាត់ | គណៈអធិបតីចូលរួម | ទីកន្លែង |
|---|---|---|---|---|---|
| ១. | ២៧/១១/២០១៤ | ស្រុកថ្មបាំង | ៦ | -អភិបាល ឬអភិបាលរងក្រុង/ស្រុក<br>និង<br>-ប្រធានក្រុមប្រឹក្សាក្រុង/ស្រុក | សាលាស្រុក |
| ២. | ២៨/១១/២០១៤ | ក្រុងខេមរភូមិន្ទ | ៣ | | សាលាក្រុង |
| ៣. | ០៥/១២/២០១៤ | ស្រុកស្រែអំបិល | ៦ | | សាលាស្រុក |
| ៤. | ០៨/១២/២០១៤ | ស្រុកមណ្ឌលសីមា | ៣ | | សាលាស្រុក |
| ៥. | ០៩/១២/២០១៤ | ស្រុកកោះកុង | ៤ | | សាលាស្រុក |
| ៦. | ១៧/១២/២០១៤ | ស្រុកគីរីសាគរ | ៣ | | សាលាស្រុក |
| ៧. | ១៨/១២/២០១៤ | ស្រុកបូទុមសាគរ | ៤ | | សាលាស្រុក |

ការបើកសិក្ខាសាលាសមាហរណកម្មផែនការឃុំ-សង្កាត់ នៅថ្នាក់ក្រុង/ស្រុកនេះ ត្រូវបានលោក-លោកស្រីជា ប្រធានមន្ទីរ អនុប្រធានមន្ទីរ ឬមន្ត្រីតំណាងមន្ទីរជុំវិញខេត្ត និង តំណាងអង្គការកម្មវិធីនានាចូលរួម ព្រមទាំងតំណាងដៃគូរ អភិវឌ្ឍន៍ វិស័យឯកជន និង សប្បុរជន ចូលរួមផងដែរ ។

សូមលោកអភិបាលក្រុង/ស្រុក រៀបចំចាត់ចែងសិក្ខាសាលាអោយបានល្អ សមស្របដូចជាទីកន្លែងសំរាប់សិក្ខាសាលា មាន តុ កៅអី ហ្មុងអក្សរ ។ល។ និង ចេញលិខិតចាត់អញ្ជើញ ប្រធានការិយាល័យ ជុំវិញក្រុង/ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាងអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលមានទីតាំងនៅ ក្នុងក្រុង/ស្រុក ទាំងអស់អោយ បានចូលរួមផងដែរ ។

- ចំពោះសាហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក ជាបន្ទុករបស់សាលា ឃុំ-សង្កាត់ សាមុី ។

ខ្ញុំមានជំនឿថា លោកអភិបាល ក្រុង/ស្រុក រៀបចំសិក្ខាសាលានេះបានល្អប្រសើរ និង សូមទទួលនូវការស្រឡាញ់ រាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

- កាលបរិច្ឆេទនេះមានសិទ្ធិកែប្រែក្នុងករណីចាំបាច់ នឹងជូនដំណឹងជាក្រោយ ។

អភិបាលខេត្ត

ប៊ុន លើត

**ចម្លងជូន:**

-ផ.អ ៣

-មន្ទីរផែនការខេត្ត

(ដើម្បីជូនជ្រាប)

- គ្រប់ក្រុង/ស្រុក ដើម្បីរៀបចំចាត់ចែង

-ឯកសារ